# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អគ្គសញ្ញាលាបថ្ងាសនៅជុំគិរី
# ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៧

អត្ថបទទី១៖ អស ២៥,៦-១០
អត្ថបទទី២៖ ភីល ៤,១២-១៤.១៩-២០
ដំណឹងល្អ៖ មថ ២២,១-១៤

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងធ្វើយ៉ាងដូចម្តេចស្តាប់ខ្លះៗ ដើម្បីទទួលការអប់រំផង ទទួលពន្លឺផង ដើម្បីឲ្យយើងយល់ថារាល់ថ្ងៃអាទិត្យយើងទុកពេលវេលា ដើម្បីកោតសរសើរព្រះជាម្ចាស់។ ថ្ងៃនេះ យើងមានអគ្គសញ្ញាលាបថ្ងាសសម្រាប់១៧នាក់ ដែលបានរៀបចំខ្លួនស្អាត ដោយសារថ្ងៃនេះយើងមកជួបជាមួយព្រះជាម្ចាស់ដើម្បីទទួលកម្លាំងយ៉ាងពិសេសពីព្រះជាម្ចាស់ ដែលយើងហៅថាព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះវិញ្ញាណដ៏វិសុទ្ធ ប្រៀបបីដូចជាដង្ហើមរបស់ព្រះជាម្ចាស់ មនុស្សយើងពេលផុតដង្ហើមមានន័យថាស្លាប់ហើយ។ ព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាជីវិត ដែលជាដង្ហើម ដែលជាកម្លាំង របស់ព្រះជាម្ចាស់ ដើម្បីឲ្យយើងជាគ្រីស្តបរិស័ទ ពោរពេញដោយសេចក្តីស្រឡាញ់ ពោរពេញដោយកម្លាំងថ្មី ដើម្បីកសាងព្រះសហគមន៍របស់យើង ដើម្បីណែនាំឲ្យក្រុមគ្រីស្តបរិស័ទយើងទាំងមូលមានជីវិត។

ដូច្នេះថ្ងៃនេះ យើងអរព្រះគុណព្រះជាម្ចាស់សម្រាប់បងប្អូនទាំង១៧នាក់ ដែលសុខចិត្តរៀបចំខ្លួនដើម្បីទទួលដង្ហើម ដើម្បីទទួលជីវិត ដែលមកពីព្រះជាម្ចាស់។ ថ្ងៃនេះយើងស្តាប់គម្ពីរ រឿងស្តេចដែលកំពុងរៀបចំពិធីមង្គលការ។ រឿងដែលយើងស្តាប់ថ្ងៃនេះប្លែក ស្តេចគាត់បានរៀបចំមង្គលការមួយយ៉ាងធំសម្រាប់កូនគាត់ ពេលដល់ម៉ោងភ្ញៀវត្រូវមកដល់ ភ្ញៀវខ្លះថារវល់ធ្វើស្រែ រវល់មើលគោ រវល់ធ្វើការមួយផ្សេងគេមិនចូលរួម។ ព្រះជាម្ចាស់ចង់បង្ហាញថា ជីវិតរបស់យើងជាគ្រីស្តបរិស័ទជាជីវិតដែលពោរពេញដោយអំណរសប្បាយ ដូចមង្គលការមួយដែលមានភ្ញៀវមកយ៉ាងច្រើន។ ព្រះជាម្ចាស់ ចង់ឲ្យយើងមានអំណរសប្បាយនៅក្នុងព្រះសហគមន៍។ នៅក្នុងមង្គលការនេះ ដែលភ្ញៀវមិនមកម្ចាស់គាត់បានប្រើអ្នកបម្រើគាត់ថា **សូមចេញទៅ ដើម្បីអញ្ជើញគេទាំងអស់នៅតាមផ្លូវ មនុស្សល្អនិងមនុស្សអាក្រក់** ព្រះជាម្ចាស់អញ្ជើញយើងឲ្យយើងចេញពីព្រះសហគមន៍របស់យើង ដើម្បីអញ្ជើញមនុស្សទាំងអស់នៅក្នុងភូមិរបស់យើង ទាំងមនុស្សល្អទាំងមនុស្សអាក្រក់ដើម្បីចូលរួមជាមួយយើងក្នុងពិធីជប់លៀងនៅក្នុងអំណរសប្បាយជាមួយព្រះជាម្ចាស់។

សម្រាប់បងប្អូនទាំងអស់គ្នា ព្រះជាម្ចាស់អញ្ជើញយើងឲ្យយើងទៅតាមកន្លែងមួយ ដើម្បីអញ្ជើញបងប្អូនឯទៀតៗឲ្យគេសប្បាយជាមួយយើងនៅក្នុងងរៀងការ។ នេះជាបេសកកម្មរបស់យើង ដែលនៅមណ្ឌលសកម្មភាពកំពតបានធ្វើច្រើន យើងមានកន្លែងថ្មីៗដែលទើបនឹងកើត ដើម្បី

អញ្ជើញបងប្អូនចូលរួមនៅក្នុងព្រះសហគមន៍យើង។ យើងដូចជាអ្នកបម្រើ ដែលព្រះជាម្ចាស់បានជ្រើសរើសឲ្យយើងចេញដើម្បីអញ្ជើញមនុស្សទាំងឡាយឲ្យមកចូលរួមមង្គលការ។ ពេលមកដល់រោងការម្ចាស់កម្មវិធីបានមកមើលភ្ញៀង ឃើញមានភ្ញៀងខ្លះមានសម្លៀកបំពាក់មិនសមរម គេក៏បណ្តេញអ្នកទាំងនោះចេញពីពីធីមង្គលការ។ ពេលយើងលឺដូចនេះយើងភ័យ មូលហេតុអ្វីធ្វើដូចនេះ? តាមប្រពៃណីនៅសម័យនោះ សាសនាយូដា នៅពេលភ្ញៀវចូលនៅក្នុងរោងការនៅពេលនោះម្ចាស់ការឲ្យអាវទៅគេតែម្តង។ ដូច្នេះ ភ្ញៀវទាំងអស់គេទទួលអាវមួយដើម្បីពាក់នៅក្នុងពិធីមង្គលការជាសញ្ញាមួយដែលយើងឯកភាពចូលរួមនៅក្នុងមង្គលការរបស់កូនគេ។ ដូច្នេះ អ្នកដែលនៅតាមផ្លូវគេឥតមានពេលដើម្បីរៀបចំខ្លួន ប៉ុន្តែនៅពេលគេឆ្លងរោងទទួលភ្ញៀវគេបានអាវមួយ មានន័យថានៅពេលនោះភ្ញៀវទាំងអស់ត្រូវមានអាវដូចគ្នា តែមានអ្នកមួយចំនួនអត់យកអាវនោះដែលជាសញ្ញាថាពួកគេមិនចង់ចូលរួមក្នុងពិធីមង្គលការនេះ ទើបម្ចាស់កម្មវធីបណ្តេញពួកគេចេញ។ ព្រះជាម្ចាស់អញ្ជើញយើង ដើម្បីឲ្យយើងរៀបចំខ្លួន ឲ្យនៅក្នុងចិត្តរបស់យើងយើងទទួលស្វាគមន៍ធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ បើយើង មិនសុខចិត្តទទួលស្វាគមន៍សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់នោះព្រះជាម្ចាស់ឲ្យយើងចេញ។ យើងធ្វើដូចម្តេច ដើម្បីទទួលសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់យើងធ្វើដូចម្តេចដើម្បីរៀបចំខ្លួនទទួលជីវិតពីព្រះជាម្ចាស់។ ព្រះជាម្ចាស់ឲ្យសេចក្តីស្រឡាញ់ មិនចង់បានអ្វីពីយើងទេ តែបើយើងមិនចង់ទទួលព្រះជាម្ចាស់មិនចង់ទទួលយើងដូចគ្នា។ សម្រាប់ព្រះសហគមន៍យើងថ្ងៃនេះ យើងមាន១៧នាក់ដែលសុខចិត្តទទួលព្រះវិញ្ញាណដ៍វិសុទ្ធ មានន័យថាសុខចិត្តទទួលជីវិតថ្មីពីព្រះជាម្ចាស់ កម្លាំងថ្មី សេចក្តីស្រឡាញ់ អំណរសប្បាយ ចិត្តអត់ធ្មត់ ចិត្តសុភាពរាបសារ ចិត្តតស៊ូពីព្រះជាម្ចាស់តែម្តង។

ប្រសិនបើយើងសុខចិត្តទទួល ព្រះជាម្ចាស់ទទួលស្វាគមន៍យើង យើងមិនពាក់អាវនិងកន្សែងយ៉ាងស្អាត សំខាន់នៅក្នុងចិត្តរបស់យើងយើងបានបំពាក់សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ឬទេ? សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ណែនាំឲ្យយើងទៅជាមនុស្សថ្មីដើម្បីចេញទៅអញ្ជើញបងប្អូនឯទៀតៗ ដើម្បីបង្ហាញធម៌មេត្តាករុណាដល់អ្នកក្រីក្រ អ្នកជំងឺ អ្នកដែលគ្មានទីពឹងអ្នកដែលអស់សង្ឃឹម។ បងប្អូនដែលទទួលអគ្គសញ្ញាលាបថ្ងាស ក៏ត្រូវចូលនៅក្នុងគម្រោងការប្រកាសដំណឹងល្អ ដោយសារយើងជាភ្ញៀវកិត្តិយសរបស់ព្រះជាម្ចាស់ យើងបានសុខចិត្តពាក់អាវដែលព្រះជាម្ចាស់ប្រទានឲ្យ គឺសេចក្តីស្រឡាញ់ អំណរ ចិត្តបរិសុទ្ធ ចិត្តអត់ធ្មត់ ការលើកលែងទោស ចិត្តតស៊ូ ជំនឿ ដែលយើងបានទទួលពីព្រះជាម្ចាស់ ណែនាំឲ្យយើងចេញដើម្បីអញ្ជើញបងប្អូនឯទៀតៗឲ្យទទួលជីវិតថ្មី។ យើងត្រូវការចេញទៅតាមភូមិនានា ដើម្បីនេសាទមនុស្សឲ្យគេស្គាល់សេចក្តីស្រឡាញ់ថែមទៀត។ អំណរសប្បាយរបស់យើង ទៅជាកម្លាំងមួយយ៉ាងពិសេសយើងជាថ្មដ៏មានជីវិត យើងមានបងប្អូនទាំងអស់ដែលជាកម្លាំង ដែលជាសេចក្តីស្រឡាញ់របស់ព្រះ

សហគមន៍។ ថ្ងៃនេះ ខ្ញុំនឹងប្រោសទឹកព្រះពរបញ្ចុះបឋមសិលាដើម្បីសាងសង់ព្រះវិហារ នៅពេលនោះយើងមានថ្មរឹងដើម្បីសាងសង់អាគារ ប៉ុន្តែសំខាន់គឺបងប្អូនដែលជាថ្មដ៏មានជីវិត ដើម្បីឲ្យព្រះសហគមន៍របស់យើងបន្តមានជីវិតនៅក្នុងអំណរសប្បាយរបស់ព្រះជាម្ចាស់។ យើងមានបងប្អូនទាំងអស់ ជាថ្មពិសេសដែលពោរពេញដោយជីវិត ស៊ីម៉ង់របស់យើងមិនមែនស៊ីម៉ង់ខេស៊ីមិន តែជាស៊ីម៉ង់ដែលមានកម្លាំងខាំគ្នាជាប់បានយូរគឺដង្ហើមរបស់ព្រះជាម្ចាស់ សេចក្តីស្រឡាញ់ដែលយើងបានទទួលពីព្រះវិញ្ញាណដ៏វិសុទ្ធ។ នេះណែនាំឲ្យព្រះសហគមន៍របស់យើងមានកម្លាំង ដូចក្រុមគ្រីស្តទូតនៅពេលគេបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ គេបានចេញដើម្បីទៅប្រកាសដំណឹងល្អ។ យើងមានសេចក្តីសុខរួមគ្នា ដើម្បីកសាងព្រះសហគមន៍ដ៏មានជីវិត យើងធ្វើដូចម្តេច ដើម្បីឲ្យព្រះសហគមន៍របស់យើងមានថ្មពិសេស បូជាចារ្យ និងបងប្រុបងស្រីយ៉ាងច្រើន។

យើងនៅស្ងៀមស្ងាត់ ទូលអង្វរព្រះវិញ្ញាណដ៏វិសុទ្ធដែលជាសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលជាដង្ហើមដែលណែនាំឲ្យយើងមានជីវិត ដើម្បីឲ្យព្រះសហគមន៍របស់យើងទៅជាព្រះសហគមន៍របស់ព្រះគ្រីស្ត ព្រះសហគមន៍ដែលចេះសម្តែងធម៌មេត្តាករុណាជានិច្ច។ អាម៉ែន៕